ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Feb-2011, 14:21
CMS/CFO: Sann Rada

## អនុស្សរណៈអន្តរការិយាល័យ

ផ្ញើរជូន: **សហមេធាវីការពារក្តីជនជាប់ចោទ** កាលបរិច្ឆេទ : ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១

A: **កាំង ហ្គេកអ៊ាវ ហៅ "ឌុច"**

យោង: សំណុំរឿងលេខ ០០១/១៨-ខែកក្កដា-ឆ្នាំ២០០៧-អវតក/អតក

ពី: **លោក ស៊ា ម៉ៅ លោក** Christopher RYAN **និង លោក ផន ធឿន,**

DE: **ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូល**

កម្មវត្ថុ: **សំណើសុំឲ្យដាក់ភស្តុតាងបន្ថែមតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង**

OBJET: **(វិសោធនកម្មលើកទី៦)**

**ជូនចំពោះ លោក ការ សាវុត្ថ និង កង ឫទ្ធារី សហមេធាវីការពារក្តី**

១. យើង ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក បានទទួលការអនុញ្ញាតដើម្បីផ្ញើរអនុស្សរណៈអន្តរការិយាល័យនេះជូនលោកសហមេធាវីការពារក្តីជនជាប់ចោទ។

២. យើងកត់សំគាល់ឃើញថា ក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់[1] និងការឆ្លើយតប[2] លោកមេធាវីធ្វើការយោង និងសំអាងលើភស្តុតាងបន្ថែមក្នុងការគាំទ្របណ្តឹងសាទុក្ខរបស់ជនជាប់ចោទប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០១។ ប្រសិន លោកមេធាវី មានបំណងសំអាងលើភស្តុតាង

---

[1] Doc. No. F14.
[2] Doc. No. F14/4/2.

បន្ថែមនេះចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល លោកមេធាវី ត្រូវធ្វើសំណើដាច់ដោយឡែកមួយសុំដាក់ភស្តុតាងបន្ថែមដែលស្របតាមវិធាន១០៨(៧)នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៦)។ សូមបញ្ជាក់ថា ភស្តុតាងបន្ថែមនេះ ត្រូវភ្ជាប់មកជាមួយនឹងសំណើនេះ ទោះបីជា វាត្រូវបានភ្ជាប់នៅក្នុងសារណាបណ្តឹងសាទុក្ខ និងចម្លើយតបរបស់ជនជាប់ចោទក៏ដោយ។

៣. ប្រសិនបើ សំណើសុំដាក់ភស្តុតាងបន្ថែម មិនស្របតាមវិធាន១០៨(៧)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូល អាចបដិសេធសំណើនេះចោលជាអសារបង់។ ប្រសិនបើ លោកមេធាវី មានបំណងសំអាងលើភស្តុតាងបន្ថែមនេះនៅក្នុងពេលសវនាការបណ្តឹងសាទុក្ខ ដោយមិនបានដាក់សំណើសុំដាក់ភស្តុតាងបន្ថែមទេនោះ អង្គជំនុំជម្រះតុលាការកំពូល អាចបដិសេធភស្តុតាងថ្មីនេះថាមិនត្រឹមត្រូវតាមទំរង់។

៤. ការសំណើណាមួយសុំដាក់ភស្តុតាងបន្ថែម ត្រូវដាក់ជាភាសាខ្មែរ និងអង់គ្លេស ឬ បារាំង ដោយមិនឲ្យហួសពីថ្ងៃចន្ទ័ **ទី២៨ ខែកុម្ភៈ ឆ្នាំ២០១១**។ ភាគីបណ្តឹងសាទុក្ខនានា ដែលទទួលរងការប៉ះពាល់ពីសំណើនេះ អាចធ្វើការឆ្លើយក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីទទួលបាននូវសេចក្តីជូនដំណឹងអំពីសំណើនេះ។

៥. សូមថ្លែងអំណរគុណដក់ការសហការលើបញ្ហានេះ។